ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០១៤

*នៅក្នុងខែកុម្ភៈនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើនដោយផ្សារភ្ជាប់បទដ្ឋាន ការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រឹទ្ធសភា នីតិកាលទី៣ ការបណ្តុះបណ្តាលធនធានមនុស្ស ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងបញ្ហាផ្សេងៗទៀត និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើតសេវាថ្មីៗ ការកសាងគោលនយោបាយនានា បង្កើនកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗ មួយចំនួនទៀតដូចខាងក្រោម៖*

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

*-បានចាត់ចែងរៀបចំកិច្ចប្រជុំ ចំនួន០១លើក ដើម្បីឆ្លងឯកសារស្តីពីសេចក្តីកំណត់ និងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ និងខ្សែវីដេអូរំលឹកខួបអនុស្សាវរីយព្រឹទ្ធសភា (ឆ្នាំទី២/នីតិកាលទី៣) ចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗ ចំនួន៥៣៣ច្បាប់ ។*

## ១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖

*-បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០១លើក ដើម្បី៖ ឆ្លងរបាយការណ៍ស្តីពីការអនុវត្តចំណូល-ចំណាយថវិកាជាតិរបស់ព្រឹទ្ធសភាឆ្នាំ២០១៣ និងកំណត់ផែនការអនុវត្តថវិកាជាតិឆ្នាំ២០១៤ របស់ព្រឹទ្ធសភា ។*

## ២.សេវាទ្រទ្រង់មុខងារតំណាង៖

*-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្ត រាជធានីទូទាំងប្រទេស ចំនួន៦៤លើក ដើម្បីសម្ពោធសាលាធម្មសភា នៅខេត្តកំពង់ស្ពឺ និងសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ*



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: oum_sarith@camnet.com.kh

នៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៨៦លើក ។

-ទទួលពាក្យបណ្ដឹងចំនួន០២ករណី និងបានទទួលលិខិតឆ្លើយតបពីក្រសួងយុត្តិធម៌ចំនួន០១ករណី ។

**៣.សេវាទ្រទ្រង់មុខងារព័ត៌មាន៖**

-បានអមដំណើរសមាជិក-សមាជិកាគណៈកម្មការនានា របស់ព្រឹទ្ធសភា បានចុះបំពេញបេសកកម្មទៅខេត្តឧត្ដរមានជ័យ ខេត្តស្ទឹងត្រែង និងខេត្តព្រះសីហនុ ដើម្បីសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយសមាគមក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជុំពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍គម្រោងវារីអគ្គិសនីសេសានក្រោម២ និងអាជីវកម្មធនធានរ៉ែ ។

**៤.ការងារអន្តរជាតិ៖**

-រៀបចំបែបបទជូនគណៈប្រតិភូព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចផ្លាស់ប្ដូរបទពិសោធន៍នៅប្រទេសឡាវ វៀតណាម និងចូលរួមការងារនៅប្រទេសឥណ្ឌូណេស៊ី និងអ៊ីរ៉ង់ កម្មសិក្សា១៧នាក់ទៅប្រទេសកូរ៉េ

-រៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍វិទ្យាស្ថានសភាកម្ពុជា

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប៊្រុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ពានកុងស៊ុលបែលហ្ស៊ិក ស្ពានកុងស៊ុលន័រវែស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៥.ទំនាក់ទំនងសាធារណៈ៖**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន៣៦០នាក់ ។

**៦.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្ដុះបណ្ដាលក្នុងប្រទេស ចំនួន០៩វគ្គ ស្ដីពីការអភិវឌ្ឍធនធានមនុស្សជំហាន២ វគ្គភាសាជប៉ុន(ជំហានទី២) វគ្គថែទាំ និងជុសជុលកុំព្យូទ័រ វគ្គMicrosoft Office Word 2010 វគ្គEnglish

Proficiency Training វគ្គASEAN Preparation Cause វគ្គបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់គ្រូបង្គោល វគ្គភាសាអង់គ្លេសសម្រាប់ការទំនាក់ទំនងពាណិជ្ជកម្មនៅក្នុងអាស៊ាន វគ្គជំនាញភាសាអង់គ្លេសកម្រិតមធ្យម និងការទំនាក់ទំនង ។

-បណ្តុះបណ្តាលមន្ត្រី០៥រូប ខាងភាសាបារាំង នៅសាលាភូមិន្ទរដ្ឋបាល ។

-មន្ត្រីចំនួន៧២នាក់ ទទួលអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ នៅតាមសាកលវិទ្យាល័យក្នុងប្រទេស ។

-មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីកម្មវិធីប្រតិបត្តិការអន្តរជាតិ សម្រាប់មន្ត្រីសភា នៅប្រទេសកាណាដា ។

**៧.ការអភិវឌ្ឍន៍ស្ថាប័នៈ**

-បញ្ចប់ការផ្ទេរទីកន្លែង និងការបំពាក់ធនធានមធ្យោបាយបន្ថែមក្នុងក្របខ័ណ្ឌអគ្គលេខាធិការដ្ឋានទាំងមូល

-ភាគីចិនកំពុងសិក្សាគំរោងសាងសង់អគារ១ខ្នង៣ជាន់ទៀត សម្រាប់ថ្នាក់ដឹកនាំបំពេញការងារ

-រដ្ឋសភាវៀតណាមឯកភាពផ្តល់ជំនួយបំពាក់ប្រព័ន្ធITនៅក្នុងព្រឹទ្ធសភាកម្ពុជា (អនុវត្តត្រីមាសទី១ ឆ្នាំ២០១៨) ។

**៨. ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែងៈ**

-មន្ត្រីជាង២០០នាក់ ត្រូវបានវាយតម្លៃ និងតម្លើងកាំប្រាក់

-បន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធ សាលប្រជុំ ការិយាល័យ ក្រោយការផ្លាស់ប្តូរទីតាំងថ្មី

-ជំរឿនទ្រព្យសម្បត្តិរដ្ឋ និងការគិតគូរដល់ដំណើរការ ប្រព័ន្ធការងារ មធ្យោបាយ និងធនធានសម្រាប់គ្រប់អង្គភាព

-មន្ត្រីរាជការបានចុះបេសកកម្មអមដំណើរគណៈប្រតិភូព្រឹទ្ធសភា ចំនួន០៥លើក

-ជូនព័ត៌មានអំពីវិស្សមកាលព្រឹទ្ធសភា ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨

-ចាត់ចែងទីតិវិធីលទ្ធកម្មសាធារណៈ ឆ្នាំ២០១៨

-ចាត់ចែងការផលិតខ្សែវីដេអូខ្លួបអនុស្សាវរីយព្រឹទ្ធសភា ប័ណ្ណជូនពរ និងសារជូនពរក្នុងឱកាសចូលឆ្នាំថ្មី

-បានបញ្ចប់ការងារប្រកាសទ្រព្យសម្បត្តិ ដើមឆ្នាំ២០១៨ (១០៦នាក់) ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន០៥លើក ។

-ថតចម្លងឯកសារ ចំនួន៨១សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន៤៣ក្បាល ដោះស្រាយសំណើថវិកា ចំនួន១៣២សំណើ និងសម្ភារចំនួន៦៣សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន១០៣លើក ។

-ប្រគល់កុំព្យូទ័រលើតុ ព្រីនធ័រ ទូទឹកកក ទូរទស្សន៍ តុកុំព្យូទ័រ ចំនួន៤៥គ្រឿង និងបំពាក់ទូរទស្សន៍ ចំនួន១១គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ បន្ទប់ទឹក ប្តូរអំពូល ព្រី កុងតាក់ ដាក់កង្ហារបឺតដោះ និងប្តូរទីតាំងទូរទស្សន៍ ចំនួន៩២គ្រឿង ។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន១៣១គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន១៧ប្រធានបទ ។

**II.ទិសដៅការងារខែមីនា ឆ្នាំ២០១៤**

១-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំវិសាមញ្ញ ព្រឹទ្ធសភា ។

២-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា ។

-ត្រៀមរៀបចំជាបន្តបន្ទាប់ជំនួបរវាងតំណាងគណបក្សប្រជាជនកម្ពុជា និងតំណាងគណបក្សសង្គ្រោះជាតិ ។

៣-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្តក្នុងរយៈពេលវិស្សមកាលរបស់ព្រឹទ្ធសភា (ថ្ងៃទី២៥ កុម្ភៈ ដល់ថ្ងៃទី២៤ ឧសភា) ។

៤-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស (មហាសន្និបាត IPU-Geneva ខែមីនា, ទស្សនកិច្ច ឡាវ វៀតណាម ម៉ាឡេស៊ី ចិន ហុងគ្រី សហរដ្ឋអាមេរិក អ៊ីរ៉ង់ វេទិកាហ្វ្រង់ កូហ្វូនីនៅទីក្រុងហូជីមិញ ។

៥-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

៦-ការត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចុះសួរសុខទុក្ខកងទ័ពនៅកោះ ពូឡូវ៉ៃ និងការកសាងអគារជូនកំលាំងនគរបាលឈរជើង នៅព្រំដែនឡាវ កម្ពុជា ( ខេត្តស្ទឹងត្រែង ) ។

៧-សិក្ខាសាលាស្តីពីវិមជ្ឈការ និងវិសហមជ្ឈការរបស់គណៈកម្មការទី៤ (ខែមីនា ) ។

៨-ជំរុញលើកកម្ពស់ចំណេះដឹង ការបើកវគ្គសិក្សាជំនាញ ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងសណ្តាប់ធ្នាប់សាធារណៈ ។

-សិក្សាលទ្ធភាពអំពីការប្រលងផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ និងការបំពេញសិទ្ធិជូនមន្ត្រីរាជការ

សាកល្បងបំពេញតួនាទីដឹកនាំ តាមអង្គភាពនានា ។

៩-សិក្សាអំពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់៤អង្គភាពជាជំហានដំបូង ។

១០-បន្តតាមដានគម្រោងសាងសង់អគារថ្មីជាមួយទីប្រឹក្សាពាណិជ្ជកម្មចិន ។

-ចាត់ចែងជួសជុល និងទំនើបកម្មសាលសិក្ខាសាលាខាងជើង-ខាងត្បូង ។ សហការជាមួយសម្ព័ន្ធភាពឃុំ-សង្កាត់ និងវិទ្យាស្ថានសភាកម្ពុជា អំពីការផ្ទេរអគារ និងជួសជុលអគារ ។

១១-បន្តពង្រឹងដំណើរការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងជំរុញការចាប់ផ្តើមដំណើរការរបស់អង្គភាពសវនកម្មផ្ទៃក្នុង ។

១២-ការរៀបចំធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិឡើងវិញ ។

១៣-បន្តអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ឥណ្ឌា និងជប៉ុន (វៀតណាមនឹងចាប់សិក្សាក្នុងខែមីនា ២០១៤) ។ ត្រៀមផ្សព្វផ្សាយខ្សែវីដេអូសម្រាប់ខួបអនុស្សាវរីយ៍ ព្រឹទ្ធសភា នីតិកាលទី៣ (២៥ មីនា ២០១៤) ។

១៤-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេសសំរាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា ។

-កិច្ចសហប្រតិបត្តិការជាមួយ KOICA, JICA, CAMSERV, VN, ឥណ្ឌូនេស៊ី សឹង្ហបុរី ម៉ាឡេស៊ី កូរ៉េ CHINA, BRUNEI វិទ្យាស្ថានធនាគារពិភពលោក វិទ្យាស្ថានសភាកម្ពុជា ។

១៥-រៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម អគារ៤ខ្នង ជាជំនួយរបស់ចិន និងអគារ២ខ្នង ជាជំនួយរបស់ជប៉ុន។ ធ្វើបច្ចុប្បន្នភាព និងថែរក្សាឯកសារសហប្រតិបត្តិការជាមួយដៃគូ ។

១៦-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារបច្ចុប្បន្នភាពរបស់ជាតិ ។

១៧-ត្រៀមរៀបចំពិធីអបអរទិវានារីអន្តរជាតិ ០៨មីនា ឆ្នាំ២០១៤ (គណៈប្រតិភូក្រសួងកិច្ចការនារី១៤៥នាក់ និងសិក្ខាសាលាអំពីការចូលរួមរបស់ស្ត្រី ដើម្បីសីលធម៌សង្គម) ។

១៨-ការត្រៀមបោះពុម្ពប័ណ្ណជូនពរ សារជូនពរ និងពិធីអបអរសាទរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ។

## III.សេចក្តីសន្និដ្ឋាន

-ក្នុងខែកុម្ភៈនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូល-ចំណាយថវិកាជាតិរបស់ព្រឹទ្ធសភា ឆ្នាំ២០១៣ និងកំណត់ផែនការអនុវត្តថវិកាជាតិឆ្នាំ២០១៤ របស់ព្រឹទ្ធសភា និងបានបញ្ចប់សេចក្តីព្រាងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ ។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋាន

ជំរុញការបណ្ដុះបណ្ដាលធនធានមនុស្ស និងបំពេញមុខងាររបស់ខ្លួនយ៉ាងសកម្ម ដោយទទួលបាន លទ្ធផលល្អប្រសើរ ។៕

ភ្នំពេញ,ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥

**អគ្គលេខាធិការ**

**អ៊ុំ សារីទ្ធ**